# ពរជ័យនៃព្រះគម្ពីរ

*អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន*
*នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

នៅថ្ងៃទី 6 ខែ តុលា ឆ្នាំ 1536 បុរសកំសត់ម្នាក់ត្រូវបានដឹកនាំចេញគុគងងឹតមួយនៅប្រាសាទ វិលវ័រឌេ ជិតប្រ៊ុសសេល បេលជីម។ អស់រយៈពេលប្រហែលជាជិតមួយឆ្នាំកន្លះ ដែលបុរសម្នាក់នោះ បាន រងទុក្ខលំបាកនៅក្នុង ភាពឯកកោរ នៅក្នុងគុកដ៏ក្រខ្វក់មួយ។ ឥឡូវនេះ នៅខាងក្រៅជញ្ជាំងប្រាសាទ អ្នក ទោសត្រូវបានចងភ្ជាប់ទៅនឹង បង្គោលមួយ។ គាត់មានពេលដើម្បីបន្លឺសម្លេងអធិស្ឋានចុងក្រោយខ្លាំងៗ ពីមុនគាត់ត្រូវប្រហាជីវិតដោយការព្យួរកថា «ព្រះអម្ចាស់ សូមបើកព្រះនេតស្តេចនៃប្រទេសអង់គ្លេស»។ រំពេចនោះរូបកាយរបស់គាត់ ត្រូវបានដុតនៅឯ បង្គោលនោះ។ តើបុរសនោះគឺជានរណា តើទោសកំហុស អ្វីដែលអជ្ញាធរទាំងផ្នែកនយោបាយ និងផ្នែកសាសនាបានផ្តន្ទាទោសដល់គាត់? គាត់ឈ្មោះ វិ ល្លិម ធីនឌេល បទឧក្រិដ្ឋរបស់គាត់ដោយសារគាត់បកប្រែ និងបោះពុម្ព ព្រះគម្ពីរបរិសុទ្ធជាភាសាអង់គ្លេស។

លោក ធីនឌេល បានកើតនៅក្នុងប្រទេសអង់គ្លេសក្នុងអំឡុងពេលដែល កូលុមប៊ុស ធ្វើដំណើរតាមទូកទៅ ទ្វីបអាមេរិក គាត់បានទទួលការអប់រំនៅមហាវិទ្យាល័យ អក់ស្វិត និងខេមប្រ៊ីច ហើយបន្ទាប់មកបានក្លាយ ទៅជាសមាជិកសាសនាកាតូលីក។ គាត់ចេះប្រាំបីភាសាយ៉ាងស្ទាត់ជំនាញរួមទាំងភាសា ក្រិច ហេព្រើរ និងឡាតាំង។ លោក ធីនឌេល គឺជាសិស្សដែលមានជំនឿស៊ប់ចំពោះព្រះគម្ពីរបរិសុទ្ធ ហើយមានចំណេះ ដឹងយ៉ាងជ្រាលជ្រៅចំពោះព្រះគម្ពីរ ដែលគាត់ ស្រាវជ្រាវ ទាំងបព្វជិត និងអ្នកមិនមែនបព្វជិត បានបង្ក បញ្ហាដល់គាត់យ៉ាងខ្លាំង។ ផ្ទុយទៅវិញ គាត់ មានការប្រកែក ជាមួយនឹងបព្វជិតម្នាក់ ដែលប្រកែកជំទាស់ ទៅនឹងការយកព្រះគម្ពីរមកឱ្យមនុស្សធម្មតា។ លោក ធីនឌេល បានសច្ចាថា៖ ប្រ៉សិនបើព្រះទុកជីវិតឱ្យ ខ្ញុំតែបន្តិចទៀត ខ្ញុំនឹងធ្វើឱ្យក្មេងប្រុសកំពុងតែព្យួរាស់ម្នាក់ ចេះដឹងព្រះគម្ពីរ ច្រើនជាង សម្តេចសង្ឃផ្ទាល់!” គាត់បានស្វែងរកការអនុមតិ ពីអ្នកមានសិទ្ធអំណាចក្នុងព្រះវិហារ ដើម្បីរៀបចំបកប្រែព្រះគម្ពីរ បរិសុទ្ធជា ភាសាអង់គ្លេស ដើម្បីឱ្យមនុស្សទាំងអស់ អាចអាន ហើយអនុវត្តន៏តាមព្រះបន្ទូលរបស់ព្រះ។ សំណើរបស់ គាត់ត្រូវបានបដិសេធ---ដោយសារទស្សនៈទូទៅមួយ ចំនួន ដែលគ្រប់គ្រងការជ្រាបចូលផ្សេងទៅក្នុង ព្រះគម្ពីរ ប៉ុន្តែពួកបព្វជិតទាំងនោះ ភ័យខ្លាចថា អំណាចនៃព្រះវិហារ គឺ ដូចគ្នានឹងការ "បោះកែវមុក្តារបស់ ខ្លួននៅមុខជ្រូក” ទោះជាយ៉ាងណាក្តី លោក ធីនឌេល បានទទួលធ្វើការបកប្រែ។ នៅក្នុង ឆ្នាំ 1524 គាត់ បានធ្វើដំណើរទៅកាន់ប្រទេសអាល្លឺម៉ង ដោយប្រើឈ្មោះក្លែងក្លាយ ដែលពេលនោះភាគច្រើន គាត់បាន រស់នៅដោយលាក់លាមស្ថិតនៅក្រោម ការចោទប្រកាន់ និងការចាប់ខ្លួន។ ដោយបានទទួលជំនួយពីមិត្ត ដែលមាន ភក្តីភាពម្នាក់ លោក ធីនឌេល អាចបោះពុម្ពការបកប្រែព្រះគម្ពីរសញ្ញាថ្មីជាភាសាអង់គ្លេស ហើយក្រោយមកបកប្រែ ព្រះគម្ពីរសញ្ញាចាស់។ ព្រះគម្ពីរបរិសុទ្ធត្រូវបានគេលួចនាំចូលប្រទេសអង់គ្លេស ដែលវាជាតម្រូវការមួយយ៉ាងខ្លាំង ហើយមានតម្លៃយ៉ាងខ្ពស់ពីសំណាក់អ្នកដែលមានលទ្ធភាពទិញ។ វា មានការចែកចាយយ៉ាងទូលំទូលាយប៉ុន្តែជាសម្ងាត់។ អជ្ញាធរបានដុតចោល ការថតចម្លងទាំងអស់ដែល

ពួកគេរកឃើញ។ ប៉ុន្តែទោះជាយ៉ាងណាក្តី កិច្ចការរបស់ លោក ធីនឌេល បានក្លាយជាគ្រឹះស្ទើរតែទាំងស្រុងចំពោះការបកប្រែព្រះគម្ពីរបរិសុទ្ធជាភាសាអង់គ្លេសនាពេលអនាគត ដែលភាគច្រើន ត្រូវបានគេស្គាល់ថា ជាការបកប្រែរបស់ឃីងជេមស៍។ 1

លោក វិល្លិម ធីនឌេល មិនមែនជាមនុស្សទីមួយ ឬមនុស្សចុងក្រោយនៃអស់អ្នកដែលនៅក្នុងប្រទេស និងក្នុងភាសា ជាច្រើនដែលមានការលះបង់នោះទេ សូម្បីតែដល់ចំណុចដែលត្រូវស្លាប់ក្តី ដើម្បីនាំយកព្រះបន្ទូលរបស់ព្រះ ចេញផុត ពីទីអាប់អួ។ យើងមានការដឹងគុណយ៉ាងធំធេងចំពោះពួកគេ។ យើងប្រហែលជាជំពាក់ពួកស្មោះត្រង់ដែលបានកត់ត្រា និងបានរក្សាព្រះបន្ទូលទាំងអស់ជាច្រើនឆ្នាំមកហើយ ជាញឹកញាប់ដោយការធ្វើពលកម្មយ៉ាងថ្មិតថ្មង់ និងការលះបង់--- ម៉ូសេ អេសាយ អ័ប្រាហាំ យ៉ូហាន ប៉ុល នីហ្វៃ មរ៉ូណៃ យ៉ូសែប ស្ម៊ីធ និងអ្នកដទៃ ទៀតជាច្រើន។ តើពួកគេបានដឹង អំពីសារៈសំខាន់នៃព្រះគម្ពីរអ្វីខ្លះដែលយើងក៏ត្រូវការដឹងផងដែរនោះ? តើមនុស្សនៅក្នុង សតវត្សរ៍ទី 16 នៃប្រទេស អង់គ្លេស ដែលបានចំណាយលុយយ៉ាងច្រើន និងលើកដាក់មកលើខ្លួននូវការប្រថុយនឹងគ្រោះថ្នាក់ ដើម្បីមានព្រះគម្ពីរបរិសុទ្ធបានយល់ឃើញថាយើងក៏គួរតែមានការយល់ដឹង ដូច្នេះផងដែររបៀបណា?

មិនយូរប៉ុន្មានមុនពេលគាត់ស្លាប់ ព្យាការីអាលម៉ា បានប្រគល់ផ្ទាំងចំណាពិសិដ្ឋដល់កូនប្រុសរបស់គាត់ ហេលេមិន ។ គាត់បានរំលឹកដល់ ហេលេមិនថា ព្រះគម្ពីរបាន «ពង្រីកស្មារតីប្រជាជននេះ មែនហើយបានបរិវត្តមនុស្សជាច្រើន អំពី កំហុសនៃផ្លូវរបស់ខ្លួន ហើយបាននាំគេអោយស្គាល់ព្រះរបស់គេ ដើម្បីឱ្យបានការសង្គ្រោះដល់ព្រលឹងគេ» (អាលម៉ា 37:8 )។ គាត់ក៏បានបញ្ជាឱ្យហេលេមិន រក្សាផ្ទាំងចំណារនោះទុក ដើម្បីតាមរយៈផ្ទាំងចំណារទាំងនោះព្រះអាច «បង្ហាញព្រះចេស្តារបស់ទ្រង់ដល់ពួកជំនាន់ក្រោយ» (អាលម៉ា 37:14 )។

តាមរយៈព្រះគម្ពីរ ព្រះពិតជាអាច «បង្ហាញព្រះចេស្តារបស់ទ្រង់» ដើម្បីសង្គ្រោះ និងលើកតំកើងកូនចៅរបស់ទ្រង់។ តាមរយៈព្រះបន្ទូលរបស់ទ្រង់ ដូចអាលម៉ា បាននិយាយថា ទ្រង់បានពង្រីកស្មារតីរបស់យើង ដើម្បីបំភ្លឺឱ្យឃើញពីកំហុស និងភាពខុសឆ្គង ហើយនាំយើងទៅរកការប្រែចិត្ត និងរីករាយក្នុងព្រះយេស៊ូវគ្រីស្ទ ដែលជាព្រះអង្គប្រោសលោះរបស់យើង។

## *ព្រះគម្ពីរពង្រីកស្មារតីរបស់យើង*

ព្រះគម្ពីរពង្រីកស្មារតីរបស់យើង តាមរយៈការជួយយើងឱ្យតែងតែចងចាំព្រះអម្ចាស់ និងទំនាក់ទំនងរបស់យើងជាមួយទ្រង់ និងជាមួយព្រះបិតា។ ព្រះគម្ពីររំលឹកដល់យើង នូវអ្វីដែលយើងបានស្គាល់នៅក្នុងជីវិតមុនជីវិតនេះ របស់យើង។ ហើយព្រះគម្ពីរបានពង្រីការចងចាំរបស់យើង នៅក្នុងវិញ្ញាណមួយផ្សេងទៀត តាមរយៈការបង្រៀនយើងអំពីយុគសម័យ ប្រជាជន និងព្រឹត្តិការណ៍នានាដែលយើងមិនបានជួបនូវ

បទពិសោធន៍ទាំងនោះដោយផ្ទាល់។ យើងទាំង អស់គ្នាគ្មាននរណាម្នាក់មានវត្តមាន មើលឃើញការញែកសមុទ្រក្រហម ហើយបានឆ្លងកាត់ចន្លោះទឹកទៅ ផ្នែកម្ខាង ទៀតឡើយ។ យើងមិនបាននៅទីនោះដើម្បីឮទេសនកថានៅលើភ្នំ មិនបានមើលឃើញឡាសារស់ឡើងវិញ ពីស្លាប់ មិនបានមើលឃើញការឈឺចាប់របស់ព្រះអង្គសង្គ្រោះនៅក្នុងសួនច្បារគែតសេម៉ានី និងនៅលើឈើឆ្កាង ហើយយើង មិនបាននៅជាមួយម៉ារី ដើម្បីឮទេវតាពីអង្គធ្វើទីបន្ទាល់នៅទីផ្នូរទទេថា ព្រះយេស៊ូវបានរស់ឡើងវិញពីសុគតហើយនោះទេ។ អ្នកនិងខ្ញុំមិនបានដើរទៅមុខម្នាក់ម្តងក្នុងចំណោមហ្វូងមនុស្សនៅលើដែនដីបរិបូរ នៅពេលព្រះអង្គសង្គ្រោះដែលមានព្រះជន្មរស់ ឡើងវិញ បាន អញ្ជើញឱ្យស្ទាបស្ទាមដែកគោល និងថើបព្រះបាទទាទ្រង់សើមជាំដោយទឹកភ្នែកនោះដែរ។ យើងមិនបានលុតជង្គង់នៅ ជិតយ៉ូសែប ស្ម៊ីធ នៅក្នុងព្រៃពិសិដ្ឋ និងបានសម្លឹងមើលព្រះវរបិតា និងព្រះជាបុត្រានោះដែរ។ ប៉ុន្តែយើងបានដឹងរឿងរ៉ាវ ទាំងអស់នេះ និងរឿងជាច្រើនទៀតរឿងរ៉ាវច្រើនជាងនេះយើងបានដឹង ពីព្រោះយើងមាន កំណត់ត្រាក្នុងព្រះគម្ពីរ ដើម្បីពង្រីកដល់ស្មារតីរបស់យើង ដើម្បីបង្រៀនយើងនូវអ្វីដែលយើងមិនដឹង។  យើងនៅពេលដែលការណ៍ ទាំងនេះ បានជ្រាបចូលក្នុងចិត្តគំនិតរបស់យើង នោះសេចក្តីជំនឿរបស់យើង ក៏បានចាក់ឫសគល់ទៅលើព្រះ និងព្រះរាបុត្រាជាទីស្រឡាញ់របស់ទ្រង់។

ព្រះគម្ពីរក៏បានពង្រីកស្មារតីរបស់យើង តាមរយៈការជួយយើងមិនឱ្យភ្លេចនូវអ្វីដែលយើង និងមនុស្សជំនាន់មុនរបស់ យើងបានរៀន។ អស់អ្នកដែលមិនមាន ឬមិនអើពើរនឹងផ្ទាំងចំណារព្រះបន្ទូលរបស់ព្រះនៅទីបំផុតឈប់មានជំនឿលើទ្រង់ ហើយក៏បានភ្លេចពីគោលបំណងនៃជីវិតរបស់ពួកគេ។ អ្នកនឹងចងចាំតើវាមានសារៈសំខាន់យ៉ាងណាសំរាប់ប្រជាជន លីហៃក្នុងការនាំយកផ្ទាំងចំណារមាសទៅជាមួយពួកគេពេលដែលពួកគេបានចាកចេញពីយេរូសាឡឹម។ព្រះគម្ពីរទាំងនេះ គឺជាគន្លឹះសំរាប់ចំណេះដឹងអំពីព្រះ និងសម្រាប់ ការប្រោសលោះ នាពេលអនាគតរបស់ព្រះគ្រីស្ទ។ មិនយូរប៉ុន្មានបន្ទាប់ មក លីហៃ គ្មានព្រះគម្ពីរហើយនៅពេល កូនចៅរបស់លីហៃបានជួបប្រទះ ប្រហែលជាបី បួនរយឆ្នាំក្រោយមក វាត្រូវបានកត់ត្រាថា៖ «ភាសារបស់ពួកគេបានក្លាយទៅជាប្រែប្រួល... ហើយពួកគេមិនទទួលស្គាល់ព្រះបង្កបង្កើតរបស់ពួកគេទេ» (អោមណៃ 1:17 )។

នៅក្នុងជំនាន់របស់ លោក ធីនឌេល ភាពអវិជ្ជាយ៉ាងខ្លាំងខ្លាចំពោះព្រះគម្ពីរ ពីព្រោះប្រជាជនខ្វះព្រះគម្ពីរបរិសុទ្ធ ជាពិសេស នៅក្នុងភាសាដែលពួកគេអាចយល់។ បច្ចុប្បន្ននេះព្រះគម្ពីរបរិសុទ្ធ និងគម្ពីរដទៃទៀតងាយស្រួលនឹងមាននៅក្នុងដៃ ប៉ុន្តែមានចំនួនមនុស្សដែលមិនអើពើនឹងព្រះគម្ពីរកាន់តែច្រើន ពីព្រោះពួកគេនឹងមិនបើកព្រះគម្ពីរទេ។ ជាលទ្ធផលពួកគេ បានបំភ្លេចនូវអ្វីដែលជីដូនជីតារបស់ពួកគេបានដឹង។

## *ព្រះគម្ពីរប្រឆាំងនឹងភាពខុសឆ្គង*

ព្រះបានប្រើព្រះគម្ពីរដើម្បីកែតំរូវគំនិតភាន់ច្រឡំ វប្បធម៌ខុសឆ្គង និងអំពើបាបដែលបំផ្លិចបំផ្លាញ។

ព្រះគម្ពីរ គឺជាឪពុក ម្តាយដ៏ទន់ភ្លន់ ដែលនឹងកាត់បន្ថយការឈឺចាប់ និងទុក្ខព្រួយដែលមិនចាំបាច់ ហើយនៅក្នុងពេលដដែលនោះជួយយើងឱ្យ ដឹងពីសក្តានុពលដ៏ទេវភាពរបស់យើង។ ឧទាហរណ៍ព្រះគម្ពីរ បានបង្ហាញកិត្យានុភាពទស្សនៈវិទូបុរាណ ដែលបានប្រែក្លាយទៅជាមានប្រជាប្រិយ៍ភាពនៅជំនាន់របស់យើង--- ទស្សនៈរបស់ កូរីហ្វ័រ គឺគ្មានបទដ្ឋាន សីលធម៌ពិតប្រាកដទេ គឺថា «មនុស្សគ្រប់រូបបានចំរើនឡើង ស្របតាមការឈ្លាសវៃរបស់ខ្លួន ហើយមនុស្សគ្រប់រូប ដណ្តើមយកស្របតាមកម្លាំង របស់ខ្លួន ហើយអ្វីៗក៏ដោយដែលមនុស្សបានប្រព្រឹត្តគឺគ្មានទោសសោះ «ហើយ កាលណា មនុស្សស្លាប់ទៅ នោះគឺជាចុងបំផុតហើយ» (អាលម៉ា 30:17--18 )។ អាលម៉ា ដែលបានប្រឈមមុខជាមួយ និងកូរីហ្វ័រ គឺមិនបានទុកឱ្យកូនប្រុសរបស់គាត់ កូរីអានតុន នៅក្នុងក្តីសង្ស័យអំពីភាពជាក់ស្តែង និងសារៈធាតនៃក្រមសីលធម៌ ដ៏ទេវភាពនោះទេ។ កូរីអានតុ ប្រព្រឹត្តបាបចំពោះការរួមភេទ ហើយឪពុករបស់គាត់បាននិយាយទៅកាន់គាត់ ដោយក្តីស្រឡាញ់ ប៉ុន្តែច្បាស់លាស់ថា៖ «កូនប្រុសរបស់ឪពុកអើយ តើកូនពុំដឹងទេឬថា អំពើទាំងនេះគឺជាអំពើគួរឱ្យខ្ពើមឆ្អើមបំផុតជាងបាបទាំងអស់ ក្រៅពីការខ្ចាយឈាមជនឥតទោស ឬបដិសេធព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ?» (អាលម៉ា 39:5 )។

បើក្រឡេកទៅក្រោយវិញជាច្រើនសតវត្សរ៍កន្លងទៅហើយ មកទល់នឹងបច្ចុប្បន្ននេះក៏មានមនុស្សជាច្រើនដែលបាន ប្រឆាំងនឹងអាលម៉ា អំពីភាពអសីលធម៌ដ៏ធ្ងន់ធ្ងរនេះ។ អ្នកផ្សេងទៀត បានប្រកែកថាវាមិនមែនជារឿងដាច់ខាតទេ ឬ សេចក្តីស្រឡាញ់របស់ព្រះមិនហាមឃាត់ទេ។ ពួកគេបាននិយាយថា ប្រសិនបើមានព្រះ នោះទ្រង់នឹងអត់ទោស ចំពោះ អំពើបាប និងអំពើអាក្រក់ទាំងអស់ ពីព្រោះសេចក្តីស្រឡាញ់របស់ទ្រង់ចំពោះយើង--- គឺមិនចាំបាច់ត្រូវការការប្រែចិត្តទេ ឬគ្រាន់តែការសារភាពធម្មតាៗនោះវាគ្រប់គ្រាន់ហើយ។ ពួកគេបានស្រមៃថា ព្រះយេស៊ូវ គ្រាន់តែចង់ឱ្យមនុស្ស ធ្វើការ សំរាប់យុត្តិធម៌សង្គមតែប៉ុណ្ណោះ ប៉ុន្តែទ្រង់មិនប៉ះពាល់ដល់ជីវិត និងអាកប្បកិរិយា ផ្ទាល់ខ្លួនឡើយ។ 2 ប៉ុន្តែជាព្រះនៃសេចក្តីស្រឡាញ់ មិនទុកឱ្យយើងរៀនសូត្រពីបទពិសោធន៍ មិនល្អដែលថា៖ «សេចក្តីទុច្ចរិតពុំដែលជា សុភមង្គលឡើយ» (អាលម៉ា 41:10 សូមមើលផងដែរ ហេលេមិន 13:38 )។ បទបញ្ញត្តិ របស់ទ្រង់គឺជាសម្លេងពិតៗ និងការពារខ្លួនយើងពីការឈឺចាប់។ ព្រះគម្ពីរបានបញ្ជាក់យ៉ាងច្បាស់ណាស់ថា សុភមង្គលគឺមិនអាស្រ័យលើការបដិសេធសេចក្តីយុត្តិធម៌នៃព្រះនោះទេ ឬក៏ព្យាយាមចៀសវាងពីផលវិបាកនៃអំពើបាបនោះដែរ ផ្ទុយទៅវិញ គឺតាមរយៈការប្រែចិត្ត និងការអភ័យទោសតាមរយៈព្រះគុណនៃដង្វាយធួននៃព្រះរាជបុត្រារបស់ព្រះប៉ុណ្ណោះ (សូមមើល អាលម៉ា 42 )។

ព្រះគម្ពីរបានបង្រៀនយើងអំពីគោលការណ៍ និងតម្លៃនៃសីលធម៌ដែលចាំបាច់ ដើម្បីរក្សាតម្លៃនៅក្នុងសង្គមស៊ីវិល រួមទាំងសេចក្តីសុចរិត ការទទួលខុសត្រូវ តម្លៃខ្លួនឯង ភក្តីភាព និងសេចក្តីសប្បុរស។ យើងរកឃើញភាពរស់រវើក នៅក្នុងការពិពណ៌នានៃពរជ័យទាំងឡាយ ដែលបានមកពីការគោរពចំពោះគោលការណ៍ពិតដ៏ដូចជាសោកនាដកម្មដែលកើតមាន នៅពេលបុគ្គល និងអារ្យធម៌ទាំងមូលបានបោះបង់វាចោល។ មិនថាជាប្រជាជនរ៉ូម ជនជាតិអាមេរិកសម័យថ្មី ឬទីកន្លែងណាផ្សេងទៀត ដែលសេចក្តីពិត

នៃព្រះគម្ពីរត្រូវបានគេមិនអើពើ ឬបោះបង់ចោល សីលធម៌ចាំបាច់ដែលជា មូលដ្ឋានគ្រឹះនៃសង្គមបាន បាក់បែក ហើយបន្តពុកផុយ។ នៅពេលនោះ គឺគ្មានអ្វីបានបន្សល់ទុកសំរាប់ទ្រទ្រង់ការស្ថាបនា ដែលទ្រទ្រង់សង្គមនោះឡើយ។

*ព្រះគម្ពីរនាំយើងទៅកាន់ព្រះគ្រីស្ទ ដែលជាព្រះប្រោសលោះរបស់យើង*

នៅទីបញ្ចប់នេះ គោលបំណងដ៏សំខាន់នៃព្រះគម្ពីរទាំងអស់ គឺដើម្បីបំពេញព្រលឹងរបស់យើង ជាមួយសេចក្តីជំនឿលើព្រះ ជាព្រះវរបិតា និងព្រះរាជបុត្រារបស់ទ្រង់គឺព្រះយេស៊ូវ គ្រីស្ទ--- សេចក្តីជំនឿដែលពួកគេមាន គឺការជឿទៅលើផែនការរបស់ព្រះវរបិតាសួគ៌សំរាប់ជីវិតរមែងស្លាប់ និងជីវិតដ៏នៅអស់កល្បរបស់យើង និងសេចក្តីជំនឿទៅលើ ដង្វាយធួន ព្រមទាំងការរស់ឡើងវិញរបស់ព្រះយេស៊ូវ គ្រីស្ទ ដែលធ្វើឱ្យផែនការនៃសុភមង្គលអាចកើតមាន សេចក្តីជំនឿដើម្បីធ្វើឱ្យដំណឹងល្អនៃព្រះក្លាយជាផ្លូវនៃជីវិតរបស់យើង និងសេចក្តីជំនឿដើម្បីដឹងថា៖ « ទ្រង់ជាព្រះដ៏ពិតតែមួយ និងព្រះយេស៊ូវគ្រីស្ទ ដែល [ទ្រង់] បានចាត់ឱ្យមកផង» (យ៉ូហាន 17:3 )។

អាលម៉ា បាននិយាយថា ព្រះបន្ទូលរបស់ព្រះ គឺដូចជាគ្រាប់ពូជដែលបានដាំនៅក្នុងដួងចិត្តរបស់យើង ដែលផ្តល់ផលឱ្យនូវ សេចក្តីជំនឿនៅពេលដែលវាចាប់ផ្តើមដុះនៅក្នុងខ្លួនយើង (សូមមើល អាលម៉ា 32:27--43 សូមមើលផងដែរ រ៉ូម 10:13--17 គ. និង ស.  50:14 )។ សេចក្តីជំនឿមិនមែនបានមកតាមរយៈការសិក្សាតាមឯកសារពីបុរាណ តាមភាសា ទាំងនោះសុទ្ធសាធនោះទេ។ វាមិនមែនបានមកពីការជីកកកាយ ឬរុករកនៃបុរាណវិទូនោះទេ។ វាមិនមែនបានមក តាមរយៈការធ្វើពិសោធន៍របស់អ្នកវិទ្យាសាស្រ្តនោះទេ។ ហើយវាក៏មិនបានមកតាមរយៈ ការធ្វើជាសាក្សីចំពោះ អព្ភូតហេតុទាំងឡាយនោះដែរ។ ការណ៍ទាំងនេះអាចបំរើឱ្យពីការបញ្ជាក់អំពីសេចក្តីជំនឿ ឬក្នុងពេលដែលមានឧបសគ្គ ប៉ុន្តែវាមិនបង្កើតសេចក្តីជំនឿនោះទេ។ សេចក្តីជំនឿបានមកពីសាក្សីនៃព្រះវិញ្ញាណបរិសុទ្ធដល់ព្រលឹងរបស់យើងតាមរយៈព្រះវិញ្ញាណទៅព្រះវិញ្ញាណ ដូចជានៅពេលដែលយើងបានឮ ឬបានអានព្រះបន្ទូលរបស់ព្រះ។ ហើយសេចក្តីជំនឿ នឹងកាន់តែចំរើនវ័យ នៅពេលដែលយើងបន្តទទូលទាននូវព្រះបន្ទូលដោយខ្ជាប់ខ្ជួន។

ដំណើររឿងក្នុងព្រះគម្ពីរបង្ហាញពីសេចក្តីជំនឿអ្នកដទៃបំរើឱ្យការពង្រឹងដល់សេចក្តីជំនឿរបស់យើង។ យើងសូមរំលឹក ឡើងវិញពីសេចក្តីជំនឿរបស់មេបញ្ជាការរ៉ូម ដែលអនុញ្ញាតឱ្យព្រះគ្រីស្ទ ព្យាបាលអ្នកបំរើរបស់គាត់ ទោះបីជាគាត់ មិនបានឃើញទ្រង់ក្តី (សូមមើល ម៉ាថាយ 8:5--13 ម៉ាកុស 7:25--30 ) និង ការព្យាបាលរបស់កូនស្រីសាសន៍ដទៃ ម្នាក់ ពីព្រោះតែម្តាយដែលមានការបន្ទាបខ្លួនព្រមទទួលយករបៀបដូចជាកំទេចដែលធ្លាក់ចុះពីតុម្ចាស់វា (សូមមើល ម៉ាថាយ 15:22--28 )។ យើងបានឮសម្រែកដ៏ឈឺចាប់របស់ យ៉ូប ថា៖ «ទោះបើទ្រង់សំឡាប់ខ្ញុំក៏ដោយ គង់តែខ្ញុំនឹង ទុកចិត្តដល់ទ្រង់ដែរ» (យ៉ូប 13:15 ) គាត់ថ្លែងទាំងទឹកភ្នែកថា៖ «ប៉ុន្តែឯខ្ញុំៗដឹងថា អ្នកដែលលោះខ្ញុំទ្រង់មាន ព្រះជន្មរស់នៅ ហើយដល់ជាន់ក្រោយទ្រង់

នឹងមកឈរនៅលើផែនដី... [ហើយ] ក្រៅពីរាងកាយនោះខ្ញុំនឹងបានឃើញ ព្រះ» (យ៉ូប 19:25 )។ យើងបានឮ និងសេចក្តីក្លាហានប្រកបដោយការប្តេជ្ញាចិត្តរបស់ព្យាការីក្មេងខ្ចីម្នាក់ ដែលត្រូវ បានមនុស្សពេញវ័យជាច្រើននាក់ស្អប់ខ្ពើម និងធ្វើទុក្ខបុកម្នេញដ៏សែនជូរចត់--- «ខ្ញុំបានឃើញការនិមិត្ត ខ្ញុំដឹងថាខ្ញុំបានឃើញការនិមិត្ត ហើយខ្ញុំពុំអាចបដិសេធរឿងនេះ ឬក៏ហ៊ានធ្វើយ៉ាងដូច្នេះបានឡើយ» (យ៉ូសែប ស្ម៊ីធ--ប្រវត្តិ 1:25 )។

ពីព្រោះពួកគេបានអធិប្បាយអំពីគោលលទ្ធិ នៃព្រះគ្រីស្ទ នោះព្រះគម្ពីរទាំងឡាយរួមជាមួយភាពជាដៃគូនៃព្រះវិញ្ញាណ បរិសុទ្ធ ដែលមានតួនាទីថ្លែងជាសាក្សី ពីព្រះវរបិតា និងព្រះរាជបុត្រា (សូមមើល នីហ្វៃទី 3 11:32 )។ ហេតុដូច្នេះ ហើយការអានព្រះគម្ពីរគឺជាវិធីមួយដែលយើងអាចទទួលព្រះវិញ្ញាណបរិសុទ្ធ។ ជាការពិតណាស់ព្រះគម្ពីរត្រូវបានប្រទានឱ្យ តាមរយៈព្រះវិញ្ញាណបរិសុទ្ធតាំងពីដំបូង (សូមមើល ពេត្រុសទី 2 1:21 និង គ. និង ស. 20:26--27; 68:4 ) ហើយព្រះវិញ្ញាណដូចគ្នានោះក៏បានបញ្ជាក់ពីសេចក្តីពិតដល់អ្នក និងដល់ខ្ញុំ។ ចូរសិក្សាព្រះគម្ពីរដោយប្រុងប្រយត្ន័ និង យកមកពិគ្រោះគ្នា។ ចូរសញ្ជឹងគិត ហើយអធិស្ឋានពីរឿងទាំងនោះ។ ព្រះគម្ពីរគឺជាវិវរណៈ ហើយវានឹងនាំមកនូវវិវរណៈ បន្ថែមទៀត។

ចូរពិចារណាអំពីទំហំនៃពរជ័យរបស់យើងក្នុងការមានព្រះគម្ពីរបរិសុទ្ធ និងទំព័រនៃព្រះគម្ពីរបន្ថែមប្រហែលជា 900 ទៀត រួមទាំងព្រះគម្ពីរមរមន គោលលទ្ធិ និងសេចក្តីសញ្ញា និងកែវមុក្តាដ៏មានតម្លៃមហិមា។ បន្ថែមពីលើនេះទៀត ចូលធ្វើការពិចារណាថា ពាក្យពេចន៍ដែលព្យាការីមានប្រសាសន៍ គឺបានឆ្លោះទៅមុខដោយសារព្រះវិញ្ញាណបរិសុទ្ធ បានរៀបចំ ដែលព្រះអម្ចាស់បានហៅថាព្រះគម្ពីរ (សូមមើល គ. និងស.68:2--4 ) ដែលបានហូរចូលមកកាន់យើង តាមរយៈទូរទស្សន៍ វិទ្យុ អ៊ិនធឺណែត ផ្កាយរណប ស៊ីឌី ឌីវីឌី និងតាមរយៈការបោះពុម្ព។ ខ្ញុំអាចស្មានបានថានៅក្នុង ប្រវិត្តសាស្ត្រ មិនធ្លាប់មានមនុស្សបានទទួលពរជ័យពីព្រះគម្ពីរដ៏បរិសុទ្ធយ៉ាងច្រើនបែបនេះឡើយ ហើយមិនតែប៉ុណ្ណោះ បុរសស្ត្រីគ្រប់រូប និងកុមារអាចមាន ព្រមទាំងអាចសិក្សាព្រះគម្ពីរចេញពីព្រះគម្ពីររបស់គាត់ផ្ទាល់ ដែលជាអត្ថបទដ៏ពិសិដ្ឋ នេះ ដែលភាគច្រើនមាននៅក្នុងភាសារបស់គាត់ផ្ទាល់។ ឱតើការណ៍នេះអស្ចារ្យយ៉ាងណា បើប្រជាជនជំនាន់ វិល្លិម ធីនឌេល មានព្រះគម្ពីរទាំងនោះដូចគ្នា ព្រមទាំងពួកបរិសុទ្ធនៅក្នុងសម័យកាន់កាប់ត្រួតត្រាមុន! ជាការពិតណាស់ ជាមួយនឹងពរជ័យទាំងនេះព្រះអម្ចាស់បានប្រាប់យើងថា យើងត្រូវប្រើព្រះគម្ពីរឱ្យបានញឹកញាប់ ព្រះគម្ពីរទាំងនោះ គឺមហិមាជាងព្រះគម្ពីរជំនាន់មុន។ ចូរយើងទទួលទានព្រះបន្ទូលរបស់ព្រះគ្រីស្ទឱ្យបានខ្ជាប់ខ្ជួន នោះវានឹងប្រាប់អ្នកនូវ ការណ៍ទាំងឡាយដែលអ្នកគួរធ្វើ (សូមមើល នីហ្វៃទី 2 32:3 )។ ខ្ញុំបានសិក្សានិងពិចារណាអំពីព្រះគម្ពីរទាំងឡាយ ហើយនៅក្នុងអំឡុងពេលបុណ្យអ៊ីស្ទើរនេះ ខ្ញុំសូមថ្លែងទីបន្ទាល់របស់ខ្ញុំទៅកាន់អ្នកអំពីព្រះវរបិតា និងព្រះរាជបុត្រា ដូចដែលបានបើកសម្តែងនៅក្នុងព្រះគម្ពីរបរិសុទ្ធ នៅក្នុងព្រះនាមនៃព្រះយេស៊ូវ គ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

- ដើម្បីជាមូលដ្ឋានគ្រឹះអំពី William Tyndale សូមមើល David Daniell, The Bible in English (Yale University Press, 2003) ទំព័រ 140—157 Lenet Hadley Read, How We Got the Bible (Deseret Book, 1985) ទំព័រ 67--74; S. Michael Wilcox, Fire in the Bones: William Tyndale, Martyr, Father of the English Bible, Deseret Book, 2004  John Foxe (បានសរសេរឡើងវិញដោយ និងធ្វើឱ្យក្លាយទៅជាបច្ចុប្បន្នភាពដោយ Harold J. Chadwick), The New Foxe's Book of Martyrs (Bridge-Logos Publishers, 1997) ទំព័រ 121--133 William Tyndale, in Wikipedia, http://en.wikipedia.org/wiki/William_Tyndale ដែលត្រូវបានបញ្ចូលនៅថ្ងៃទី 28 ខែ កុម្ភៈ ឆ្នាំ 2010។
- សូមមើលការសម្ភាសន៍របស់ Richard Neitzel Holzapfel នៅក្នុង Michael De Groote, «Questioning the alternative Jesus» Deseret News, Mormon Times ថ្ងៃទី 29 ខែ វិច្ឆិកា ឆ្នាំ 2009។